# គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣
# ករណីសិក្សា

| | |
|---|---|
| ស៊ីស៊ីចេប/ផ្នែកទី២ ៖ ទ.ប.ស.ស<br>អ្នកដែលបំពេញបែបបទ ៖<br>ឈ្មោះ ៖ គ្រុយ សុវណ្ណសិរីរ័ត្ន<br>តួនាទី ៖ មន្ត្រីសម្របសម្រួល ខេត្តកំពង់ចាម | ខែ ឧសភា ឆ្នាំ ២០១១<br>បុគ្គល/ក្រុមដែលត្រូវធ្វើសម្ភាសន៍ ៖<br>ឈ្មោះ ៖ ជា ពៅ អាយុ ៖ ២០ឆ្នាំ<br>ភេទ ៖ ប្រុស ភូមិ ៖ ទ្រៀក ឃុំ ៖ បង្គោ ស្រុក ៖ មេមត់ ខេត្ត ៖ កំពង់ចាម |

**ទិសដៅ**

យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រ៤ នៃកម្មវិធីទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍ គឺការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងជំរុញឲ្យមានឥរិយាបថល្អៗសំរាប់សង្គម តាមរយៈការផ្តល់សេវាផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច និងអប់រំ ដោយផ្តោតជាពិសេសទៅ លើក្រុមងាយរងគ្រោះដូចជា ស្ត្រី អនីតិជន និងយុវជនដែលមានឥរិយាបថអាចពាក់ព័ន្ធទៅនឹងបទល្មើសឬរងគ្រោះដោយសារបទល្មើស។

ករណីសិក្សាខាងក្រោមនេះ គឺជាឧទាហរណ៍មួយនៃការគាំទ្រ របស់គម្រោង ស៊ីចេប.ស៊ី. ដែលបានចូលរួមចំណែកធ្វើអោយសហគម៌មានភាពរុងរឿងប្រកបដោយបរិស្ថានសុវត្ថិភាព និងសន្តិសុខល្អ។

**ដំណើររឿង**



យុវជន ជា ពៅ មានអាយុ ២០ឆ្នាំ គឺជាកូនទី១០ក្នុងគ្រួសារកសិករមួយ ដែលមានជីវភាពក្រីក្រ។ ជា ពៅ បានសិក្សាត្រឹមថ្នាក់ទី១០ថ្មី ហើយបានបោះបង់ការសិក្សាចោលរួចហើយបានសេពគប់ជាមួយមិត្តភ័ក្រ្តដែលជាក្រុមក្មេងទំនើង និងធ្លាប់ឈ្លោះ វាយតប់គ្នាក្នុងសាលារៀនជាមួយ



ក្រុមនេះជាញឹកញាប់ ព្រមទាំងរំខានដល់ការសិក្សា។ ក្រោយពីបោះបង់ការសិក្សារបស់ខ្លួននៅឆ្នាំ ២០០៩ យុវជន ជាពៅ រូបនេះពុំមានការងារធ្វើណាមួយឲ្យបានច្បាស់លាស់ ដើម្បីរកប្រាក់

ចំណូលសម្រាប់ផ្គត់ផ្គង់ដល់គ្រួសារឡើយ ។ លើសពីនេះទៅទៀត គឺគាត់ចូលចិត្តដើរលេងជាមួយមិត្តភ័ក្រ្ត រហូតឈានដល់ដំណាក់កាលប្រើប្រាស់ថ្នាំញៀនមួយរយៈពេលខ្លីផងដែរ ។

## ការជួយអន្តរាគមន៍

នៅឆ្នាំ២០១០ ការិយាល័យសង្គមកិច្ចស្រុក បានចុះអនុកិច្ចសន្យាជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ស្រុកមេមត់ បានធ្វើការផ្សព្វផ្សាយស្តីពីការជ្រើសរើសយុវជនយុវនារីដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ក្រោមជំនួយរបស់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣។

ពេលនោះ យុវជន ជា ពៅ ត្រូវបានមេភូមិជ្រើសរើសឲ្យចូលរៀនវគ្គផ្សព្វផ្សាយស្តីពីការជំរុញសកម្មភាពបង្ក្រាបល្បែងស៊ីសង ការប្រមូលក្មេងទំនើង ក្មេងប្រើប្រាស់គ្រឿងញៀន ដើម្បីយកមកអប់រំណែនាំ និងធ្វើកិច្ចសន្យាឲ្យបញ្ឈប់សកម្មភាពនានាដែលផ្ទុយពីច្បាប់ ។

ដោយយោងតាមលក្ខណៈវិនិច្ឆ័យ យុវជន ជា ពៅ បានទទួលជោគជ័យក្នុងការជ្រើសរើសឲ្យចូលរួមវគ្គបណ្តុះបណ្តាលមុខជំនាញជួសជុលម៉ូតូ ។

## ការផ្លាស់ប្តូរឥរិយាបថ

លោកគ្រូបង្រៀនវគ្គបណ្តុះបណ្តាលមុខជំនាញជួសជុលម៉ូតូបានប្រសាសន៍ថា យុវជន ជា ពៅ មានការអត់ធ្មត់ តស៊ូ ខិតខំប្រឹងប្រែងរៀនសូត្រ និងមិនចំណាយពេលវេលាដោយឥតប្រយោជន៍ ព្រមទាំងចូលរួមជាមួយកម្មវិធីផ្សព្វផ្សាយផ្សេងៗក្នុងមូលដ្ឋានគ្រប់ពេលទាំងអស់។ ឥឡូវនេះ គាត់មិនដូចពេលមុន គឺគាត់លែងចូលចិត្តដើរលេងជាមួយមិត្តភ័ក្រ្ត និងឈប់ប្រើប្រាស់ថ្នាំញៀនទៀតផង ។



លោក គី វ៉ាន់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលបាន អង្កេតឃើញថា មួយរយៈកន្លងមកនេះ គាត់ពុំបានបង្កបញ្ហា ឬ ឈ្លោះប្រកែកគ្នាដូចពេលមុននោះឡើយគឺគាត់កំពុងសិក្សាមុខជំនាញជួសជុលម៉ូតូពិតមែន។ លើសពីនេះ យុវជនរូបនេះបានជួយណែនាំបន្តដល់មិត្តភ័ក្រ្តដ៏ទៃមិនឲ្យប្រព្រឹត្តសកម្មភាពដែលខ្លួនយល់ថាមិនល្អចំពោះសហគមន៍ និងសង្គមជាតិទៀតផង ។

លោក ទិត រិន ជាមេភូមិបង្គោ បានបញ្ជាក់ថា យុវជនជាពៅ បានកែប្រែជាមនុស្សថ្មីមួយរូបនៅក្នុងភូមិ ដែលធ្វើឲ្យអ្នកភូមិ ស្រលាញ់រាប់អាន។ ជួនកាល គាត់បាន

ជួយជួសជុលម៉ូតូឲ្យអ្នកភូមិដោយមិនយកប្រាក់ទៀតផង។ ជាមួយគ្នានេះដែរ លោកមេភូមិក៏បានថ្លែងអំណរគុណដល់ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ដែលបានអនុវត្តន៍នៅក្នុងភូមិរបស់លោក ហើយសូមឲ្យកម្មវិធីនៅតែបន្តជួយដល់ភូមិបង្គោលទៅទៀត។

យុវជន ជា ពៅ សំដែងការដឹងគុណដល់លោកមេភូមិ អាជ្ញាធរស្រុក និងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ ដែលបានផ្តល់ឱកាសដ៏មានតំលៃដល់ខ្លួនឲ្យទទួលបានមុខជំនាញពិតប្រាកដ និងសូមអោយកម្មវិធីនេះបន្តការគាំទ្របន្តទៅទៀត ដើម្បីអោយយុវជនយុវនារីក្នុងភូមិនេះមានមុខជំនាញ និងការងារធ្វើគ្រប់គ្នាដើម្បីជួយកសាង និងអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិឲ្យមានភាពរីកចម្រើនជឿនលឿន៕